ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមប្រកាសជូនសាធារណជនឲ្យបានជ្រាបថា កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំពិធីសំណេះសំណាលជាមួយក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច នៅសណ្ឋាគារកាំបូឌីយ៉ាណា។ បន្ទាប់ពីកិច្ចសំណេះសំណាលជាមួយបណ្តាក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចរួចមក ក៏មានសារព័ត៌មានមួយចំនួនបានធ្វើការផ្សាយពីការប្រមូលថ្លៃឈ្នួលដីសម្បទានក្នុងឆមាសទី១ ឆ្នាំ២០១៦ បានប្រមាណ ៦០ម៉ឺនដុល្លារអាមេរិក ដោយធ្វើការរិះគន់ និងធ្វើការគណនាក្រៅផ្លូវការតាមទំហំផ្ទៃដីគុណនឹងតម្លៃត្រូវបង់៥ដុល្លារក្នុង១ហិកតាយកតែម្តង ដែលខុសពីនីតិវិធីមានចែងក្នុងកិច្ចសន្យា។

ដើម្បីចៀសវាងនូវការភ័ន្តច្រឡំ និងចុះផ្សាយហួសពីការពិត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការបញ្ជាក់ជូនថា រហូតមកទល់បច្ចុប្បន្នមានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២២៣ក្រុមហ៊ុន មានផ្ទៃដីសរុបចំនួន១.៥៥២.៧០០ហិកតា។ ប៉ុន្តែផ្ទៃដីដែលធ្វើអាជីវកម្មជាក់ស្តែងមានចំនួន១.០៦៩.០០០ហិកតាប៉ុណ្ណោះ ក្នុងនោះ ក្រុមហ៊ុនចំនួន១១២ពុំទាន់ត្រូវបានអនុវត្តកាតព្វកិច្ចបង់ថ្លៃឈ្នួលទេ ហើយកំពុងដំណើរការបង្វែរមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រង គឺ ៧៣ក្រុមហ៊ុនត្រូវផ្ទេរពីក្រសួងបរិស្ថាន ៣២ក្រុមហ៊ុនដែលមានផ្ទៃដីតូចជាង១.០០០ហិកតាចុះកិច្ចសន្យាជាមួយអនុគណៈកម្មការខេត្ត និង៧ក្រុមហ៊ុនទៀតពុំទាន់បានចុះកិច្ចសន្យា។ ក្រុមហ៊ុនចំនួន១១១ទៀតកំពុងដំណើរការស្ថិតក្រោមការគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែមានក្រុមហ៊ុនចំនួន១០១ជាក្រុមហ៊ុនដល់ឆ្នាំត្រូវបង់ថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច និង១០ក្រុមហ៊ុនទៀតពុំទាន់គ្រប់៦ឆ្នាំក្រោយពេលឈូសឆាយនៅឡើយ។ ដូចនេះ គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រមូលបានឈ្នួលដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន២១ក្រុមហ៊ុន ស្មើទឹកប្រាក់ប្រមាណ៦០ម៉ឺនដុល្លារ ហើយរំពឹងថានឹងប្រមូលបន្តរហូតដល់ដំណាច់ឆ្នាំ២០១៦អាចកើនឡើងជិត២លានដុល្លារ។ ការប្រមូលនេះពុំមែនក្រុមហ៊ុនទាំងអស់សុទ្ធតែត្រូវបង់ថ្លៃសម្បទានដីសេដ្ឋ-កិច្ចក្នុងពេលតែមួយព្រមគ្នានោះទេ គឺទៅតាមពេលវេលា ដំណាក់កាលនៃការចុះកិច្ចសន្យា ទំហំដីអាចធ្វើអាជីវកម្មបានតាមលិខិតអនុញ្ញាតឲ្យឈូសឆាយ ហើយគិតចាប់ពីឆ្នាំទី៦តទៅ។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន តាមការគួរ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320